ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦ . អនក្រ . បក

# អនុក្រឹត្យ

ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ២៩០ហិកតា និង១០ហិកតា ស្ថិតក្នុងតំបន់ឧទ្យានជាតិព្រះស្ទឹងរាម-ក្បាលឆាយ ក្នុងសមៈ "គីរីរម្យ" និង ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ខេត្តកំពង់ស្ពឺ

PheakdeyLaw Book Store

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ ដោយចីរភាព ។

យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១: -**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ **២៥០(ពីររយហាសិប)ហិកតា**ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ទេសចរណ៍ និងផ្ទៃដី**១០**(ដប់)ហិកតា សម្រាប់រៀបចំជាវិទ្យាស្ថាន និងថ្នាលបណ្តុះកូនឈើ ស្ថិតនៅក្នុងតំបន់ទ្រនាប់ឆ្លងកាត់ រវាងតំបន់ឧទ្យានជាតិសុភាម្រិត-កុសមៈ គីរីរម្យ និងឧទ្យានជាតិព្រះមុនីវង្ស បូកគោ ខេត្តកំពង់ស្ពឺ ដូចមានក្នុងផែនទីជូនភ្ជាប់ មកជាមួយ និងនិយាមកាដូចខាងក្រោម :

| ID | N | X | Y | ID | N | X | Y |
|---|---|---|---|---|---|---|---|
| 1 | A | 397755 | 1237229 | 8 | H | 395501 | 1236032 |
| 2 | B | 398010 | 1236196 | 9 | I | 396016 | 1236327 |
| 3 | C | 396850 | 1235793 | 10 | J | 396006 | 1236547 |
| 4 | D | 396605 | 1235625 | 11 | K | 396066 | 1236597 |
| 5 | E | 396097 | 1235651 | 12 | L | 395926 | 1237012 |
| 6 | F | 395707 | 1235334 | 13 | M | 395566 | 1236924 |
| 7 | G | 395227 | 1235754 | | | | |

**មាត្រា២: -**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយ ក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

បណ្ណាគារ ភក្តីឡដ៍
PheakdeyLaw Book Store

**មាត្រា៣: -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤ -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ




| ID | N | X | Y |
|---|---|---|---|
| 1 | A | 397755 | 1237229 |
| 2 | B | 398010 | 1236196 |
| 3 | C | 396850 | 1235793 |
| 4 | D | 396605 | 1235625 |
| 5 | E | 396097 | 1235651 |
| 6 | F | 395707 | 1235334 |
| 7 | G | 395227 | 1235754 |
| 8 | H | 395501 | 1236032 |
| 9 | I | 396016 | 1236327 |
| 10 | J | 396006 | 1236547 |
| 11 | K | 396066 | 1236597 |
| 12 | L | 395926 | 1237012 |
| 13 | M | 395566 | 1236924 |